Vol 5, No 1, January - June 2020, pp: 51 - 58
License: CC BY 4.0

**Faculty Publications**
ISSN: 3008-1017
Title DOI: https://doi.org/10.62458/021024

# Parliamentary Sovereignty: Theory, Practice and Beyond

**Virak Prum***

## ABSTRACT

As the world's best known parliamentary system, Great Britain's constitutional and legal structure has had to endure life as a compliant member of the greater European Union. As the UK is now set to leave the EU, this note aims to provide an insight into this theoretically odd EU-UK relationship. It begins with the concept of sovereignty as understood in the Continental Europe. It then highlights key points of the UK's peculiar concept of parliamentary sovereignty. Perhaps Brexit could positively make the UK more seriously consider adopting a written constitution after all.

**Key words:** representation, sovereignty, constitution.

* Virak Prum, PhD
CamEd Business School
Email: moni@cam-ed.com

# ទ្រឹស្តីអធិបតេយ្យ

## សញ្ញាណនៃការតំណាង

អធិបតេយ្យ សំដៅលើអំណាចគ្រប់គ្រងដែលបុគ្គលមួយក្រុមទទួលបានតាមរយៈការផ្ទេរ សិទ្ធិពីប្រជាពលរដ្ឋទាំងមូល។ អធិបតេយ្យ រឺ អំណាចគ្រប់គ្រង កើតឡើងតាមរយៈការសម្តែងឆន្ទៈរបស់ប្រជាពលរដ្ឋដែលសុខចិត្តផ្តល់អាណត្តិជាក់លាក់អោយទៅបុគ្គលមួយក្រុម ព្រោះប្រជាពលរដ្ឋដែលជាម្ចាស់អំណាចពុំអាចទៅដឹកនាំដោយផ្ទាល់គ្រប់ៗគ្នាបានទេ។ ក្នុងន័យនេះ យើងឃើញថាមានការបែងចែករវាងម្ចាស់ពិតនៃអំណាចដែលមិនអាចប្រើអំណាចនោះបានដោយខ្លួនឯង និងក្រុមអ្នកតំណាងដែលបានទទួលសិទ្ធិពីម្ចាស់ក្នុងការប្រើអំណាចនោះ។ [2] នៅពេលដែលប្រជាពលរដ្ឋបានផ្ទេរអំណាចនេះទៅអោយអ្នកតំណាងរួចហើយ (តាមរយៈការបោះឆ្នោត) ប្រជាពលរដ្ឋពុំអាចផ្ទេរអំណាចដដែលនេះទៅអោយក្រុមណាមួយផ្សេងទៀតបានឡើយ។ ក្នុងន័យនេះហើយដែលគេនិយាយថា អធិបតេយ្យ ពុំអាចដោះដូរ រឺ ផ្ទេរបានទៀតទេនៅក្នុងអាណត្តិដដែលនោះ។

## សញ្ញាណនៃអធិបតេយ្យ [3]

ក្នុងប្រព័ន្ធ*ប្រជាធិបតេយ្យដោយតំណាង* អ្នកដឹកនាំទទួលបានអំណាច(អធិបតេយ្យ)ដែលតាមពិតខ្លួនមិនមែនជាម្ចាស់ទេ ព្រោះប្រជាពលរដ្ឋទើបជាម្ចាស់នៃអំណាច។ ក្នុងបរិបទដែលប្រជាពលរដ្ឋទើបជាម្ចាស់នៃអំណាច ពាក្យអធិបតេយ្យមានន័យថាម៉េចទៅ? ជាបឋម ពាក្យថា អធិបតេយ្យជាចរិកលក្ខណៈពិសេសមួយរបស់រដ្ឋដែលធ្វើអោយរដ្ឋក្លាយជាស្ថាប័នខ្ពស់ជាងគេបំផុតក្នុងប្រទេស។ នៅលើឆាកអន្តរជាតិ រដ្ឋអធិបតេយ្យពុំអាចចំនុះក្រោមរដ្ឋណាមួយទៀតឡើយ។ម្យ៉ាងទៀត ពាក្យថា អធិបតេយ្យ ក៏អាចសំដៅលើអំណាចរបស់ស្ថាប័នដែលនៅខ្ពស់ជាងគេក្នុងឋានានុក្រម ។ ក្នុងន័យនេះគេអាចនិយាយអំពីអធិបតេយ្យសភាដែលផ្តល់ដល់សភានូវអំណាចធ្វើច្បាប់គ្រប់បែបយ៉ាង រឺក៏អធិបតេយ្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែលផ្តល់ដល់ក្រុមប្រឹក្សានេះនូវអំណាចធ្វើសេចក្តីសម្រេចបិទផ្លូវតវ៉ាជាដើម។ ក្នុងអត្ថន័យចំបងទាំងពីរខាងលើនេះ អធិបតេយ្យពុំអាចត្រូវបានដោះដូរ រឺ ផ្ទេរបានទេ ព្រោះថាស្ថាប័ន រឺ អំណាចដែលខ្ពស់ជាងគេមិនអាចមានលើសពីមួយបានឡើយ។

ចរិកលក្ខណៈមួយទៀត គឺថាអធិបតេយ្យពុំអាចបំបែកបានឡើយ ព្រោះថាបើអធិបតេយ្យត្រូវបានបំបែកជាជំរាកៗដើម្បីផ្ទេរទៅអោយស្ថាប័នពីរ រឺ ច្រើនក្នុងពេលជាមួយគ្នានោះ ពុំអាចមានស្ថាប័នណាមួយដែលខ្ពស់ជាងគេកើតទេ។ បើសិន ជាត្រូវមានស្ថាប័នលើសពីមួយ នោះអធិបតេយ្យត្រូវប្រើរួមគ្នាដើម្បីចេញសេចក្តីសម្រេចរួមបាន ដូចក្នុងករណីរដ្ឋសភានិងព្រឹទ្ធសភាដែលត្រូវអនុម័តលើអត្ថបទច្បាប់តែមួយព្រោះជា អធិបតេយ្យតែមួយ។

[2] Francis Hamon and Michel Troper (2016-2017). Droit Constitutionnel. 37e edition. L.G.D.J, p. 177. ជាក់ស្តែងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៥១ចែងថា *“អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន**តាមរយៈ**រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។”*

[3] Ibid., 185.

## អធិបតេយ្យរាស្ត្រ [4]

គួររំលឹកថាអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋជាបណ្ដុំនៃរូបវន្តបុគ្គលដែលអាចប្រើអំណាចនោះបាន។ ហេតុនេះ ទើបគេនិយាយថា ទ្រឹស្ដីអធិបតេយ្យរាស្ត្រ មានភាពស៊ីសង្វាក់គ្នាទៅនឹងទ្រឹស្ដី*ប្រជាធិបតេយ្យដោយផ្ទាល់*។ ដោយសារប្រជាពលរដ្ឋជាបណ្ដុំមនុស្សពិតប្រាកដ ទ្រឹស្ដីប្រជាធិបតេយ្យដោយផ្ទាល់អនុញ្ញាតអោយប្រជាពលរដ្ឋមានលទ្ធភាពសម្ដែងនូវឆន្ទៈរបស់ខ្លួនផ្សេងពីឆន្ទៈរបស់មេដឹកនាំបាន។ ទ្រឹស្ដី*អធិបតេយ្យរាស្ត្រ*នេះ នាំមកផលវិបាកបីយ៉ាង:

១. ដោយសារមានតែប្រជាពលរដ្ឋប៉ុណ្ណោះដែលជាម្ចាស់អំណាច ការបោះឆ្នោតជ្រើសរើសមេដឹកនាំ គឺជាសិទ្ធិដែលម្ចាស់អំណាចមានពេញទី។ ហេតុដូចនេះហើយ ទើបសិទ្ធិបោះឆ្នោតត្រូវតែផ្ដល់អោយទៅប្រជាពលរដ្ឋគ្រប់ៗគ្នាដែលគេហៅថា ការបោះឆ្នោតជាសកល ។

២. បើកលទ្ធភាពមួយចំនួន ដើម្បីអោយប្រជាពលរដ្ឋអាចអនុវត្តអំណាចដោយផ្ទាល់ បានជាក់ស្ដែងតាមរយៈការធ្វើប្រជាមតិ ដូចនៅប្រទេសបារាំងជាដើម។

៣. ទទួលស្គាល់អោយពលរដ្ឋមានអំណាចអាជ្ញាបញ្ជាពោលគឺសិទ្ធិដាក់ការងារឬបញ្ជាដាក់លាក់ទៅអ្នកតំណាងរបស់ខ្លួនដែលត្រូវអនុវត្តតាម។

## អធិបតេយ្យជាតិ [5]

ខុសពីពាក្យប្រជាពលរដ្ឋ ពាក្យថាប្រជាជាតិ (Nation) បង្កប់នូវអត្ថន័យអរូបី ដែលរាប់បញ្ចូល ទាំងប្រជាពលរដ្ឋទាំងជំនាន់តកូនតចៅ ទាំងផលប្រយោជន៍ទូទៅរបស់ជាតិ។ ដូចនេះ ប្រជាជាតិមិនមែនសំដៅតែទៅលើប្រជាពលរដ្ឋដែលរូបីប៉ុណ្ណោះទេ។ ក្នុងអត្ថន័យ អធិបតេយ្យជាតិនេះ ម្ចាស់ រឺ ប្រភពនៃអំណាច (អធិបតេយ្យ) ពុំមែនប្រជាពលរដ្ឋទេ តែគឺជាប្រជាជាតិដែលអរូបីនេះឯង។ ហេតុនេះគោលការណ៍ *អធិបតេយ្យជាតិ*ញ៉ាំងអោយមានផលវិបាកផ្ទុយពីគោលការណ៍អធិបតេយ្យរាស្ត្រត្រង់ថា:

១. ពុំអនុញ្ញាតិអោយប្រជាពលរដ្ឋទៅដឹកនាំដោយផ្ទាល់បានទេ (គ្មានប្រជាធិបតេយ្យដោយផ្ទាល់ទេ គ្មានប្រជាមតិទេ)។

២. ការអនុវត្តអំណាចក្នុងការជ្រើសរើសអ្នកតំណាង រឺ អ្នកដឹកនាំក្លាយមកជាការអនុវត្តភារកិច្ច រឺ ករណីយកិច្ចជាជាងការអនុវត្តសិទ្ធិ ដូចក្នុងទ្រឹស្ដីអធិបតេយ្យរាស្ត្រ។

៣. អ្នកតំណាងរាស្ត្រជាប់ឆ្នោតក្លាយជាអ្នកតំណាងប្រជាជាតិទាំងមូល ដើម្បីការពារផលប្រយោជន៍ប្រជាជាតិទូទៅទាំងមូល (មិនមែនត្រឹមតែផលប្រយោជន៍មណ្ឌលបោះឆ្នោតរបស់ខ្លួនទេ)។ ដូចនេះប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួនគ្មានអាណត្តិអាជ្ញាបញ្ជាទេ។[6]

ខាងលើគឺជាការបង្ហាញត្រួសៗពីទ្រឹស្ដីអធិបតេយ្យដែលមានប្រភពពីឧបទ្វីបអឺរ៉ុប (Continental Europe) ដែលរដ្ឋនានានៅទីនោះសុទ្ធតែមានរដ្ឋធម្មនុញ្ញសរសេរទាំងអស់ (ដូចជា បារាំង អាល្លឺម៉ង់ អ៊ីតាលី អេស្ប៉ាញ ជាដើម) ក្នុងខណៈដែលអង់គ្លេសជា

[4] Ibid., 187.

[5] Ibid.

[6] ដូចនៅបារាំងដែរ រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៧៧ ចែងថា អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ។

រដ្ឋសមាជិកសហភាពអឺរ៉ុបតែមួយគត់ដែលគ្មានរដ្ឋធម្មនុញ្ញសរសេរ។ ការដឹកនាំតាមបែបប្រជាធិបតេយ្យទាមទារអោយមានរដ្ឋសភាតំណាងប្រជាជនមួយ ដែលមានអំណាចអនុម័តច្បាប់ដើម្បីយកទៅអនុវត្តលើផ្ទៃប្រទេសទាំងមូល។ បញ្ហានៅត្រង់ថា តើសភានេះ គួរមានអំណាចគ្មានព្រំដែនដែរ ឬ ទេ។ នៅប្រទេសដែលមានរដ្ឋធម្មនុញ្ញសរសេរ ភាគច្រើនរដ្ឋធម្មនុញ្ញរបស់គេតែងបានកំណត់ច្បាស់អំពីអំណាចរបស់រដ្ឋសភា និងថែមទាំងមានស្ថាប័នរដ្ឋមួយចាំឃ្លាំមើលថាតើច្បាប់របស់សភាផ្ទុយពីរដ្ឋធម្មនុញ្ញឬអត់ (បារាំងមានក្រុមប្រឹក្សាធម្មនុញ្ញ អ៊ីតាលីមានតុលាការធម្មនុញ្ញ ។ល។)។ ចុះក្នុងករណីអង់គ្លេសដែលគ្មានរដ្ឋធម្មនុញ្ញសរសេរ [7] តើគេអាចកំណត់ព្រំដែនអំណាចរបស់សភាបានឬទេ?

# ទ្រឹស្តីសភាអធិបតេយ្យបែបអង់គ្លេស

## ការវិវត្តនៃអំណាចសភានៅអង់គ្លេស

កាលពីសម័យដើម ស្តេចនៅអង់គ្លេសមានអំណាចពេញបរិបូរគ្មានព្រំដែន អាចដឹកនាំ និង ចេញបញ្ញត្តិច្បាប់ដោយពុំចាំបាច់ពិគ្រោះយោបល់ជាមួយស្ថាប័ន ឬ បុគ្គលណាមួយឡើយ។ ប៉ុន្តែនៅឆ្នាំ ១២៦៥ លោក Simon de Montfort បានប្រមែប្រមូលតំណាងប្រជាជនក្នុងតំបន់នានាមកប្រជុំក្នុងរូបភាពជាសភាតែមួយជាលើកដំបូងបង្អស់ ដើម្បីផ្តល់យោបល់ដល់ស្តេច Henry III។ នេះ ជាលើកដំបូងហើយ ដែលស្ថាប័នពិគ្រោះយោបល់មានរាប់បញ្ចូលនូវតំណាងពីអាជ្ញាធរដែនដី និង តំណាងពីគហបតី។ តមកទៀត នៅឆ្នាំ ១៤៨៥ ទើបមានការទទួលស្គាល់ថា បញ្ញត្តិដែលចេញដោយ ព្រះមហាក្សត្រ និង ដែលបានពិគ្រោះយោបល់ជាមួយសភាមានអានុភាពអាចកែប្រែ Common Law [8] បាន ដែលធ្វើអោយអំណាចរបស់ស្តេចកាន់តែកើនខ្លាំងឡើងៗ ជាពិសេសស្តេច Henry VIII ។ ក្រោយមកទៀត បុត្រីរបស់ព្រះអង្គដែលបានក្លាយជាមហាក្សត្រយានីឈ្មោះ Elizabeth I បានប្រែក្លាយព្រះរាជបល្ល័ង្ក អោយទៅជាអំណាចកំពូលនៅលើបុគ្គល និង គ្រប់វិស័យ ថែមទាំងនៅពីលើព្រះវិហារទៀតផង។

---

[7] "រដ្ឋធម្មនុញ្ញឥតសរសេរ" មានចំនួនតិចណាស់។ ក្នុងចំណោមរដ្ឋធំៗ មានតែចក្រភពអង់គ្លេសតែប៉ុណ្ណោះដែលនៅប្រើរដ្ឋធម្មនុញ្ញទំនៀមទម្លាប់នេះ ក៏ប៉ុន្តែ រដ្ឋធម្មនុញ្ញទំនៀមទម្លាប់របស់អង់គ្លេសមានរាប់បញ្ចូលនូវបទប្បញ្ញត្តិសរសេរជាច្រើនៈ អត្ថបទ Magna Carta ឆ្នាំ១២១៥, The Petition of Rights ១៦២៨, Habeas Corpus ១៦៧៩, Bill of Rights ១៦៨៩, ច្បាប់បង្កើតប្រទេស ១៧០១ និងច្បាប់ដទៃទៀត រួមមានច្បាប់បង្កើតសហគមន៍អ៊ឺរ៉ុប ១៩៧២, និងច្បាប់សិទ្ធិមនុស្ស ១៩៩៨ ជាដើម។ល។ នៅអង់គ្លេស អត្ថបទគតិយុត្តទាំងអស់នេះសុទ្ធតែមានតម្លៃជារដ្ឋធម្មនុញ្ញ។ ឧទាហរណ៍ជាក់ស្តែងដែលបញ្ជាក់ពីតម្លៃនៃទំនៀមទម្លាប់ (ឥតសរសេរ) នៅអង់គ្លេសរួមមាន ការរំលាយសភាជាន់ទាប កាតព្វកិច្ចរបស់ព្រះមហាក្សត្រត្រូវជ្រើសតាំងនាយករដ្ឋមន្ត្រីពីប្រធានបក្សឈ្នះឆ្នោតច្រើនជាងគេ បំរាមមិនឱ្យព្រះមហាក្សត្រធ្វើជាអធិបតីគណរដ្ឋមន្ត្រី...ជាដើម សុទ្ធសឹងជាវិធានទំនៀមទម្លាប់ឥតសរសេរទាំងអស់ ដែលត្រូវបានគេទទួលស្គាល់តៗគ្នាថាមានតម្លៃ គតិយុត្តស្មើរដ្ឋធម្មនុញ្ញនៅអង់គ្លេស។ *See* A W Bradley, K D Ewing & C J S Knight (2015). *Constitutional & Administrative Law*. 16th edition. London: Pearson.

[8] "ប្រព័ន្ធ Common Law មានដើមកំនើតនៅអង់គ្លេស។ នៅឆ្នាំ ១០៦០ ស្តេចឈ្មោះ William បានចូលទន្រ្ទានប្រទេសអង់គ្លេស ហើយអនុវត្តគោលនយោបាយកែលំអច្បាប់អង់គ្លេសជាបណ្តើរៗ។ ប៉ុន្តែ William យកចិត្តទុកដាក់មិនចង់អោយប្រជាជនអង់គ្លេសចាត់ទុកទ្រង់ជាអ្នកឈ្លានពានទេ តែចង់អោយគេចាត់ទុកទ្រង់ជាក្សត្របន្តរាជ្យដោយសន្តិភាព។ ក្នុងគោលនយោបាយបន្តនិរន្តរ៍ភាពនេះ William មិនបំបាត់ចោលនូវប្រពៃណីទំនៀមទំលាប់ និង ប្រព័ន្ធតុលាការដែលមានស្រាប់នៅអង់គ្លេសឡើយ បានន័យថា តុលាការតាមតំបន់នីមួយៗនៅបន្តធ្វើសេចក្តីសម្រេចទៅតាមទំនៀមទំលាប់ពីដើមរៀងៗខ្លួន។ និយាយម្យ៉ាងទៀត ប្រទេសអង់គ្លេសពុំមានប្រព័ន្ធច្បាប់ឯកភាពតែមួយទេ។ បន្ទាប់មក William ក៏បង្កើតនូវក្រុមចៅក្រមក្នុងរាជវាំង Westminster ដែលចាប់ផ្តើមពីយុត្តាធិការដែលគ្របដណ្តប់លើប្រភេទរឿងក្តីមួយចំនួនតូចប៉ុណ្ណោះ ប៉ុន្តែយុត្តាធិការនេះ បានពង្រីកគ្របដណ្តប់លើរឿងក្តីផ្សេងៗ រហូតដល់ឥទ្ធិពលរបស់តុលាការតាមតំបន់ត្រូវបានសាបរលាភជាបណ្តើរៗ។ សេចក្តីសម្រេចរបស់ក្រុមចៅក្រមក្នុងរាជវាំងនេះ ក៏ក្លាយជាប្រភពនៃច្បាប់សម្រាប់យកទៅអនុវត្តដូចគ្នានៅគ្រប់ទិសទីនៅប្រទេសអង់គ្លេស។ ចលនានេះ បានបង្កើតជាបណ្តើរៗនូវប្រព័ន្ធច្បាប់មួយដែលទទួលបានការអនុវត្តដូចៗគ្នា (common) ចំពោះរឿងក្តីស្រដៀងគ្នា។ នេះ ហើយជាអ្វីដែលគេហៅថា Common Law។" Extract from Virak Prum (2018) *A Note on Legal Methods: Recent Caselaw in Cambodia*. Available at: https://cam-ed.com/file/researchonwebsite/Virak%20Prum-%20A_Note_on_Legal_Methods%20_in_Cambodia.pdf (last accessed in November 2019).

ស្តេចទាំងពីរអង្គនេះ បានប្រមែប្រមូល និង បង្កើនអំណាចរបស់ខ្លួនដោយខ្ចីដៃពីសភា។ ការចេញបទប្បញ្ញត្តិដោយស្តេច គឺធ្វើតាមរយៈការពិគ្រោះយោបល់ជាមួយសភា ដែលគេហៅថា "King in Parliament"។ ក្រុមរាជានិយមជឿថា អំណាចធ្វើច្បាប់ជាអំណាចរបស់ព្រះមហាក្សត្រ ព្រោះទ្រង់មានសិទ្ធិក្នុងនាមជាអ្នកតំណាងរបស់ព្រះ ដែលអនុវត្តសិទ្ធិនោះ ដោយមានការយល់ព្រមពីតំណាងគហបតី។ ដោយឡែក ក្រុមគាំទ្រសភា លើកឡើងថា គឺសភាទាំងពីរទៅវិញទេ ដែលគប្បីមានអំណាចធ្វើច្បាប់ពិតប្រាកដ ហើយអនុវត្តអំណាចនេះ ដោយមានការចូលរួមពីព្រះមហាក្សត្រ។ [9]

## ខ្លឹមសារនៃសភាអធិបតេយ្យ

នៅប្រទេសអង់គ្លេស ទ្រឹស្តីសភាអធិបតេយ្យ ឬ បរមានុភាពសភា (parliamentary sovereignty ឬ legislative supremacy) ត្រូវបានពិភាក្សា អត្ថាធិប្បាយ ពន្យល់ ដោយអ្នកប្រាជ្ញជាច្រើន ជាពិសេសដោយសាស្រ្តាចារ្យ Dicey តាមរយៈសៀវភៅរបស់គាត់ឈ្មោះ The Law of The Constitution ដែលត្រូវបានបោះពុម្ពលើកទី ១០ ក្នុងឆ្នាំ ១៩៥៩។ បរមានុភាព (supremacy) ឬ អធិបតេយ្យ (sovereignty) របស់សភា មានន័យថា អំណាចរបស់សភាគ្មានព្រំដែនឡើយ។ សាស្រ្តាចារ្យ Dicey បានសរសេរថា "សភាមានអំណាចធ្វើច្បាប់អ្វីក៏ដោយ ឬ លុបច្បាប់អ្វីក៏ដោយតាមចិត្តចង់ ហើយពុំមានបុគ្គល ឬស្ថាប័នណាមួយមានសិទ្ធិលើសសភា ឬ មានសិទ្ធិមិនអនុវត្តអ្វីដែលសភាបានអនុម័តបានឡើយ"។ និយាយម្យ៉ាងទៀត មានន័យថា សភាមានអំណាចធ្វើច្បាប់គ្រប់គ្រងលើវិស័យទាំងអស់ដោយពុំមាន ស្ថាប័នណាមួយផ្សេងទៀតមានអំណាចធ្វើច្បាប់ ឬ មានអំណាចដាក់ព្រំដែនលើសភាបានឡើយ។ [10]

## ចរិកលក្ខណៈគតិយុត្តនៃគោលការណ៍សភាអធិបតេយ្យ

ក្នុងការអនុវត្តន៍ជាក់ស្តែង គោលការណ៍បរមានុភាពសភា ឬ សភាអធិបតេយ្យនេះ ទាមទារអោយតុលាការត្រូវអនុវត្តតាមច្បាប់ដែលសភាបានអនុម័ត ដោយពុំមានសិទ្ធិធ្វើមោឃភាព លើច្បាប់ណាមួយ ឬ ប្រកាសថាច្បាប់ណាមួយអធម្មនុញ្ញបានឡើយ។ និយាយអោយខ្លី តុលាការអាចធ្វើត្រឹមតែអនុវត្តតាមច្បាប់ប៉ុណ្ណោះ។ ជាក់ស្តែងក្នុងរឿងក្តី *Madzimbamuto V Lardner-Burke* នៅឆ្នាំ ១៩៦៩ ដែលទាក់ទងនឹងការប្រកាសឯករាជ្យដោយឯកតោភាគីរបស់ដែនដី Rhodesia ដើម្បីផ្តាច់ខ្លួនចេញពីអង់គ្លេស ។ ចៅក្រម Lord Reid បានសរសេរថា៖

[9] A W Bradley, K D Ewing & C J S Knight (2015), *ibid.*, 45.

[10] ក្នុងការអនុវត្តន៍ជាក់ស្តែង មានចៅក្រមល្បីៗមួយចំនួនជឿថាគោលការណ៍គ្រឹះខ្លះអាចធ្វើអោយសភាខ្លាចរអារនឹងរំលោភដែរ ដូចជាគោលការណ៍នីតិរដ្ឋ គោលការណ៍ឯករាជ្យភាពតុលាការ គោលការណ៍ត្រួតពិនិត្យនីត្យានុកូលភាព ជាដើម។ ទោះបីជាគ្មានការការពារពីរដ្ឋធម្មនុញ្ញសរសេរដូចក្នុងប្រទេសដ៏ទៃទៀតក៏ដោយ ក៏តុលាការនៅអង់គ្លេសបានបង្កើតនិងពង្រឹងអំណាចរបស់ខ្លួនដោយខ្លួនឯង ព្រោះថានៅទីបំផុតរាល់សំណួរទាក់ទងនឹងច្បាប់គឺត្រូវឆ្លើយដោយតុលាការដដែលទេ។ តាមធម្មតាសភាអង់គ្លេសតែងគោរពគោលការណ៍នីតិរដ្ឋស្រាប់ហើយ តែបើតុលាការនៅតែទើសចិត្តនឹងទង្វើរបស់សភាហើយសម្រេចថាច្បាប់ណាមួយត្រូវមោឃៈ នោះតុលាការហាក់ដូចជាបានចាកឆ្ងាយពីពិភពច្បាប់ និងបានឈានចូលមកពិភពនយោបាយហើយ។ *See* H.W.R Wade & C.F. Forsyth (2014) *Administrative Law*, 11th edition. Oxford University Press: Oxford, p. 22-23.

ជារឿយៗ តែងមានមតិលើកឡើងថា សភារបស់ចក្រភពអង់គ្លេសពុំគួរធ្វើទង្វើមួយចំនួន ព្រោះទង្វើនេះ អាចផ្ទុយពីរដ្ឋធម្មនុញ្ញ ដោយហេតុថាមានហេតុផលនយោបាយ ឬ សីលធម៌ ឬ ហេតុផលផ្សេងទៀត ដែលខ្លាំងលើសលប់ពេកដែលញ៉ាំងអោយទង្វើរបស់សភាទៅជាមានភាពមិនប្រក្រតី បើសភានៅតែធ្វើបែបនោះ។ ប៉ុន្តែនោះមិនមែនមានន័យថា សភាគ្មានអំណាចធ្វើទង្វើនោះទេ។ បើសិនជាសភាសម្រេចចិត្តធ្វើដូចនោះមែន តុលាការពុំអាចប្រកាសមោឃភាពលើទង្វើនោះបានឡើយ។[11]

ដូចនេះ ក្នុងគោលការណ៍បរមានុភាពសភា មានតែច្បាប់ដែលអនុម័តដោយសភាទេ ទើបអាចទទួលបានផលប្រយោជន៍ពីគោលការណ៍នេះបាន។ សេចក្តីសម្រេចជាច្រើនផ្សេងៗទៀតពុំមានតម្លៃជាបរមានុភាពសភាទេឧទាហរណ៍ដូចជា:

- Resolution របស់សភាតំណាងអង់គ្លេស (House of Commons)
- បទបញ្ជាដែលចេញដោយរដ្ឋាភិបាល ឬ រដ្ឋមន្ត្រី
- ច្បាប់ដែលអនុម័តដោយសភាស្កុតឡែន ឬ សភារបស់អៀកឡង់ខាងជើង
- បញ្ញត្តិដែលចេញដោយអាជ្ញាធរដែនដីជាដើម។

នៅក្នុងករណីខាងលើនេះ ចៅក្រមត្រូវធ្វើការពិចារណាថាតើ បញ្ញត្តិខាងលើនេះ មានអានុភាពចាប់បង្ខំអោយអនុវត្តបានដែរ ឬទេ។ ដូចគ្នាដែរ នៅពេលដែលភាគី លើកអំណះអំណាង ដោយពឹងផ្អែកទៅលើបញ្ញត្តិនៃច្បាប់ណាមួយរបស់សភាចក្រភពអង់គ្លេស ចៅក្រមក៏ត្រូវត្រួតពិនិត្យផងដែរ ថាតើបញ្ញត្តិនោះចូលជាធរមានហើយឬនៅ។ [12]

## ទំនាក់ទំនងរវាងគោលការណ៍សភាអធិបតេយ្យ និង នីតិអន្តរជាតិ

ក្រោមទ្រឹស្តីសភាអធិបតេយ្យ ចៅក្រមមិនអាចធ្វើមោឃភាពលើច្បាប់ ដោយសំអាងថា ច្បាប់នោះ ផ្ទុយពីគោលការណ៍ទូទៅនៃនីតិអន្តរជាតិ ឬ ផ្ទុយពីសន្ធិសញ្ញាដែលអង់គ្លេសជារដ្ឋហត្ថលេខីឡើយ។ ប៉ុន្តែជាទូទៅ សភាអង់គ្លេសតែងប្រុងប្រយ័ត្ន ដោយពុំអនុម័តច្បាប់ណាដែលផ្ទុយពីក្របខណ្ឌនៃសហគមអន្តរជាតិឡើយ។ ទោះបីជារដ្ឋាភិបាលជាអ្នកធ្វើសេចក្តីសម្រេចខាងផ្នែកនយោបាយ ថាតើគួរចូល ឬ មិនចូលជាសមាជិកនៃសន្ធិសញ្ញាអន្តរជាតិណាមួយ មានតែសភាទេដែលមានអំណាចផ្តល់សច្ចាប័ន លើសន្ធិសញ្ញានោះ ដែលតាមរយៈការផ្តល់សច្ចាប័ននេះ សន្ធិសញ្ញាក្លាយជាច្បាប់ដែលតុលាការជាតិត្រូវអនុវត្ត។ ជាការពិតណាស់ ពេលដែលរដ្ឋាភិបាលចុះហត្ថលេខាលើសន្ធិសញ្ញាអន្តរជាតិ ទង្វើនេះបង្កើតនូវសម្ពាធផ្នែកនយោបាយ នូវក្តីសង្ឃឹមធម្មនុរូបដែលរដ្ឋហត្ថលេខីដទៃទៀត សង្ឃឹមថា អង់គ្លេសនឹងអនុវត្តតាមសន្ធិសញ្ញានោះ។ ប៉ុន្តែក្រោមទ្រឹស្តីសភាអធិបតេយ្យ រដ្ឋសភាអង់គ្លេសគ្មានកាតព្វកិច្ចត្រូវផ្តល់សច្ចាប័ននោះទេ។ ដូចនេះ យើងលើកយកទំនាក់ទំនងរវាងច្បាប់អង់គ្លេស និង ច្បាប់សហភាពអឺរ៉ុបមកពិចារណា។

The European Court of Justice បានចេញយុទ្ធសាស្ត្រតាំងពី ឆ្នាំ ១៩៦៤ ហើយដែលត្រូវបានពង្រឹងសារជាថ្មីនៅ ឆ្នាំ ១៩៧០ ថា ច្បាប់របស់សហភាពអឺរ៉ុបមានឧត្តមានុភាពលើច្បាប់ជាតិ: "ច្បាប់ដែលកើតចេញពីសន្ធិសញ្ញា មានប្រភពឯករាជ្យពី

[11] *Madzimbamuto V Lardner-Burke* [1969] 1 AC 645, 723.

[12] A W Bradley, K D Ewing & C J S Knight (2015), *op cit*., 50-51.

ច្បាប់ជាតិ ហេតុនេះ មិនអាចត្រូវបានកែប្រែជំនួសដោយច្បាប់ជាតិឡើយ"[13]។ តាមរយៈច្បាប់ឈ្មោះ European Communities Act 1972 ដែលសភាអង់គ្លេសបានអនុម័ត អង់គ្លេសបានចូលជាសមាជិកនៃសហភាពអឺរ៉ុបចាប់ពី ឆ្នាំ ១៩៧៣[14] ដែលតាមរយៈការក្លាយខ្លួនជាសមាជិកនេះ អង់គ្លេសត្រូវទទួលស្គាល់និងអនុវត្តរាល់បញ្ញត្តិទាំងអស់របស់សហភាពអឺរ៉ុបដែលមាន*អានុភាពអនុវត្តផ្ទាល់* (direct effect) ក្នុងរដ្ឋជាសមាជិកទាំងអស់។ អានុភាពអនុវត្តនេះ សំដៅទៅលើ សន្ធិសញ្ញា និង បញ្ញត្តិនៅពេលបច្ចុប្បន្ន ក៏ដូចជាសន្ធិសញ្ញា និង បញ្ញត្តិក្នុងពេលអនាគត។ នេះបានន័យថា ដរាបណា អង់គ្លេសនៅតែជាសមាជិករបស់សហភាពអឺរ៉ុប រដ្ឋសភាអង់គ្លេសពុំមែនជាស្ថាប័នតែមួយដែលមានអំណាចធ្វើច្បាប់ផ្តាច់មុខសម្រាប់ប្រទេសអង់គ្លេសឡើយ ព្រោះបញ្ញត្តិច្បាប់ទាំងអស់របស់សហភាពអឺរ៉ុបក៏មានអានុភាពអនុវត្តផ្ទាល់នៅអង់គ្លេសដែរ។ ជាផលវិបាក ចៅក្រមអង់គ្លេសមិនត្រូវយកច្បាប់អង់គ្លេសមកប្រើទេ ប្រសិនបើច្បាប់នោះផ្ទុយពីបញ្ញត្តិរបស់សហភាពអឺរ៉ុប។

ក្នុងរឿងក្តី Factortame (No 2 ឆ្នាំ ១៩៩១) ដ៏ល្បីល្បាញ ចៅក្រម Lord Bridge បាននិយាយថាៈ

> ទោះបីជា គោលការណ៍ឧត្តមានុភាពនៃច្បាប់សហភាពអឺរ៉ុប លើច្បាប់ជាតិ ពេលខ្លះពុំបានត្រូវចែងច្បាស់នៅក្នុងសន្ធិសញ្ញាក៏ដោយ ក៏យុទ្ធសាស្ត្ររបស់ European Court of Justice បានទទួលស្គាល់យកគោលការណ៍នេះ តាំងពីមុនពេលដែលអង់គ្លេសចូលសមាជិកសហគមអឺរ៉ុបម្ល៉េះ។ ហេតុដូច្នោះ អង់គ្លេសសុខចិត្តដាក់ព្រំដែនលើអធិបតេយ្យខ្លួនឯងដោយស្ម័គ្រចិត្ត នៅពេលដែលខ្លួនអនុម័ត European Communities Act 1972 ដែលតាមរយៈនេះ ចៅក្រមអង់គ្លេសមានកាតព្វកិច្ចអនុវត្តច្បាប់របស់សហគមអឺរ៉ុបដោយរំលងច្បាប់ជាតិណាដែលផ្ទុយពីច្បាប់សហគមអឺរ៉ុប។ ដូចគ្នានេះដែរ ពេលដែលសេចក្តីសម្រេចរបស់ European Court of Justice បានចង្អុលបង្ហាញថា ច្បាប់អង់គ្លេសណាមួយពុំអនុលោមតាមសារាចរណ៍ ក្រុមប្រឹក្សាអឺរ៉ុប "រដ្ឋមន្ត្រីអឺរ៉ុប" សភាអង់គ្លេសតែងតែទទួលយកកាតព្វកិច្ចមកអនុវត្តដោយធ្វើវិសោធនកម្ម ដើម្បីតម្រូវតាមច្បាប់របស់អឺរ៉ុប...។[15]

អតីតសាស្ត្រាចារ្យ Sir William Wade បានហៅសេចក្តីសម្រេច Factortame ខាងលើថា ជា "បដិវត្តន៍រដ្ឋធម្មនុញ្ញ" ព្រោះ "សភាឆ្នាំ ១៩៧២ បានទទួលជោគជ័យក្នុងការដាក់កម្រិតលើអធិបតេយ្យរបស់សភាឆ្នាំ ១៩៨៨ ដែលធ្លាប់ជាបាតុភូតមួយដែលតែងត្រូវបានគេចាត់ទុកថា មិនអាចធ្វើទៅរួច"។[16] នេះក៏ព្រោះតែក្នុងទ្រឹស្តីនីតិរដ្ឋធម្មនុញ្ញអង់គ្លេស តាមរយៈគោលការណ៍បរមានុភាពសភា សភាក្នុងនីតិកាលមួយ ពុំអាចចងសភានានីតិកាលបន្តបន្ទាប់បានទេ ដោយសារសភាថ្មីមានអំណាចពេញទី ក្នុងការកែប្រែ ឬ លុបចោលនូវអ្វីដែលសភាមុនបានអនុម័ត ព្រោះអង់គ្លេសពុំមានរដ្ឋធម្មនុញ្ញសរសេរតឹងរឹងមួយ ដែលបញ្ញត្តិទុកនូវគោលការណ៍មួយចំនួនដែលហាមសភាតាមនីតិកាលនីមួយៗពុំអោយកែប្រែឯណា។

---

[13] Case 6/64, Costa v ENEL, [1964] ECR 585 និង Case 11/70, Internationale Handelsgesellschatf case [1970] ECR 1125, 1134.

[14] The European Economic Communities ត្រូវបានបង្កើតក្នុងឆ្នាំ ១៩៥៧ ដោយរដ្ឋស្ថាបនិកចំនួនប្រាំមួយគឺ West Germany, France, Italy, Belgium, the Netherlands និង Luxembourg។

[15] *Cited in* A W Bradley, K D Ewing & C J S Knight, *op cit*., 135.

[16] (1996) 112 Law Quarterly Review 568។ រឿងក្តី Factortame នេះ ទាក់ទងទៅនឹងការព្យួរការអនុវត្តន៍ច្បាប់ Merchant Shipping Act 1988 ជាបណ្តោះអាសន្នដោយរង់ចាំសេចក្តីសម្រេច European Court of Justice ពាក់ព័ន្ធនឹងការចុះបញ្ជីកប៉ាល់នៃសាទសញ្ជាតិអង់គ្លេស។

# សេចក្តីសន្និដ្ឋាន

ដោយស្ថិតក្រោមសំពាធនយោបាយផ្ទៃក្នុងដែលទាមទារអោយស្តារឡើងវិញនូវអធិបតេយ្យសភារបស់ខ្លួន រដ្ឋាភិបាលចម្រុះដែលកើតចេញពីការបោះឆ្នោតឆ្នាំ២០១០បានប្រញ៉ាប់ប្រញ៉ាល់ដាក់អោយសភាអង់គ្លេសអនុម័តច្បាប់ European Union Act នៅឆ្នាំ ២០១១ ដែលបង្កើតលក្ខខណ្ឌថ្មីចំនួនពីរ ចំពោះរាល់ការកែប្រែសន្ធិសញ្ញារបស់ EU ក៏ដូចជាការពង្រីកអំណាចរបស់ស្ថាប័ននានារបស់ EU: ទី ១. ទាមទារអោយមានការអនុម័តពីសភា និង ទី ២. ទាមទារអោយមានការយល់ព្រមពីប្រជាមតិ។ ដូចនេះ ការផ្តល់សច្ចាប័នពីសភាតែមួយពុំគ្រប់គ្រាន់ទេ ទាល់តែប្រជាពលរដ្ឋយល់ព្រមបន្ថែមទៀតទើបបាន។ លក្ខខណ្ឌទី១ជានិស្ស័យខាងផ្លូវច្បាប់ (ឈរលើអធិបតេយ្យជាតិ) រីឯលក្ខខណ្ឌទី២មានចរិតនយោបាយជាប្រជាធិបតេយ្យដោយផ្ទាល់ (បង្ហាញពីអធិបតេយ្យរាស្ត្រ)។ តាំងពីឆ្នាំ១៩៧៣មកដល់ឆ្នាំ២០១៩ អស់រយះកាលជិត៥០ឆ្នាំ ទំនាក់ទំនង EU-UK បានឆ្លងកាត់ភាពតានតឹងផ្នែកនយោបាយ និងជាពិសេស ភាពស្រពិចស្រពិលផ្នែកច្បាប់ដែលកើតឡើងពីគោលការណ៍សភាអធិតេយ្យអង់គ្លេសនេះឯង។ ទោះជាមានច្បាប់ឆ្នាំ២០១១ក៏ដោយ ក៏នាឆ្នាំ២០១៦ប្រជាមតិនៅអង់គ្លេសបានសម្រេចអោយអង់គ្លេសចាកចេញពីសហភាពអឺរុប។ ព្រឹត្តការណ៍នេះហាក់បង្ហាញអោយឃើញថាដរាបណាអង់គ្លេស នៅតែអោបក្រសោបគោលការណ៍សភាអធិបតេយ្យតាមន័យដើមរបស់លោក Dicey ការខិតខំបញ្ចូលអង់គ្លេសទៅក្នុងក្របខណ្ឌច្បាប់អន្តរជាតិដែលមានអានុភាពអនុវត្តផ្ទាល់ទំនងជាមិនមានលទ្ធផលយូរអង្វែងទេ។

សម្រាប់អ្នកទ្រឹស្តីច្បាប់ បទពិសោធន៍នៃជីវិតរបស់អង់គ្លេសដែលជាប្រទេសគ្មានរដ្ឋធម្មនុញ្ញសរសេរក្នុងការរស់នៅជាគ្រួសារតែមួយជាមួយបណ្តុំប្រទេសដែលសុទ្ធតែឈរលើរដ្ឋធម្មនុញ្ញសរសេរ បានបង្ហាញថាទំនាក់ទំនង EU-UK ជាទំនាក់ទំនងដែលពិបាកទ្រទ្រង់ណាស់ ព្រោះអាចរក្សាបានតែក្នុងពេលដែលនៅមានការគាំទ្រពីសភា(នយោបាយដឹកមុខច្បាប់)តែប៉ុណ្ណោះ ពោលគឺពុំមែនជាទំនាក់ទំនងដែលឈរលើមូលដ្ឋានច្បាប់រឹងមាំដែលមានរដ្ឋធម្មនុញ្ញជាបង្អែកទេ។[17] នៅប្រទេសដែលមានរដ្ឋធម្មនុញ្ញសរសេរ ភាគច្រើនរដ្ឋធម្មនុញ្ញតែងបានកំណត់ច្បាស់អំពីអំណាចរបស់រដ្ឋសភា និងថែមទាំងមានស្ថាប័នរដ្ឋមួយចាំឃ្លាំមើលថាតើសភាបានប្រព្រឹត្តផ្ទុយរដ្ឋធម្មនុញ្ញឬអត់។ ដោយសារសភាថ្មីមានអំណាចពេញទីក្នុងការកែប្រែ ឬ លុបចោលនូវអ្វីដែលសភាមុនបានអនុម័តនោះ បទពិសោធន៍ពីទំនាក់ទំនង EU-UK ប្រហែលជានឹងជុំរុញអោយអង់គ្លេសរឹតតែចង់តាក់តែងរដ្ឋធម្មនុញ្ញសរសេរមួយដូចប្រទេសដទៃនាពេលឆាប់ៗខាងមុខ។

[17] ជាក់ស្តែងសភាអង់គ្លេសបានអនុម័តច្បាប់ European Union (Withdrawal) Act 2018 ដែលបានចែងថាច្បាប់ European Communities Act 1972 ត្រូវនិរាករណ៍នៅថ្ងៃអង់គ្លេសចាកចេញពី EU។